ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

អគ្គិសនីកម្ពុជា

លេខ: ៣២៩២ អដណ.នទក.មអជ

ថ្ងៃ ពុធ ០១ រោច ខែ ចេត្រ ឆ្នាំរោង ឆស័ក ព.ស.២៥៦៧

រាជធានីភ្នំពេញ, ថ្ងៃទី ២៤ ខែ មេសា ឆ្នាំ២០២៤

# សេចក្តីជូនដំណឹង

**អគ្គិសនីកម្ពុជា** មានកិត្តិយសសូមជម្រាបជូនសាធារណជនឲ្យបានជ្រាបថា ក្រោមការយកចិត្តទុកដាក់ខ្ពស់ក្នុងការលើកកម្ពស់កម្រិតជីវភាពរបស់ប្រជាពលរដ្ឋនៅតំបន់ជនបទ **រាជរដ្ឋាភិបាលកម្ពុជា** មានឆន្ទៈជំរុញការអភិវឌ្ឍវិស័យថាមពលអគ្គិសនីដើម្បី "ឈានទៅសម្រេចឲ្យបានការផ្គត់ផ្គង់ថាមពលអគ្គិសនីមួយគ្រប់គ្រាន់មានចីរភាព អាចទុកចិត្តបាន មានគុណភាព និងមានថ្លៃសមរម្យសម្រាប់អ្នកប្រើប្រាស់គ្រប់ប្រភេទ នៅគ្រប់ទីកន្លែងទូទាំងព្រះរាជាណាចក្រកម្ពុជា"។ **អគ្គិសនីកម្ពុជា** បន្តផ្តល់ថវិកាជាអំណោយដល់នាយកដ្ឋានមូលនិធិអគ្គិសនីការូបនីយកម្មជនបទ (ហៅកាត់ថា "ម.អ.ជ.") ដើម្បីបន្តអនុវត្ត **"កម្មវិធីជួយទុនសម្រាប់ពង្រីក និងកែលម្អការផ្គត់ផ្គង់អគ្គិសនីនៅតំបន់ជនបទ"** ដោយកម្មវិធីនេះនិងបន្តអនុវត្តក្នុងឆ្នាំ២០២៤។ គោលបំណងនៃកម្មវិធីនេះ គឺជួយសម្រួលដល់សេវាករអគ្គិសនីនៅតំបន់ជនបទដែលមានអាជ្ញាបណ្ណស្របច្បាប់មានទុន សម្រាប់វិនិយោគពង្រីក និងកែលម្អការផ្គត់ផ្គង់អគ្គិសនីឲ្យពេញដែនអាជ្ញាបណ្ណរបស់ខ្លួន ដើម្បីឲ្យប្រជាពលរដ្ឋជនបទគ្រប់គ្រួសារអាចភ្ជាប់ចរន្តប្រើប្រាស់តាមលទ្ធភាពរបស់ខ្លួន។ ក្រោមកម្មវិធីនេះ ម.អ.ជ.នឹងផ្តល់ប្រាក់កម្ចីដោយពុំយកការប្រាក់សម្រាប់វិនិយោគលើការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធអគ្គិសនីនៅតំបន់ជនបទ ដែលមានដង់ស៊ីតេប្រជាពលរដ្ឋរស់នៅមធ្យម និង ម.អ.ជ. នឹងផ្តល់ប្រាក់ឧបត្ថម្ភធនមួយផ្នែកបន្ថែមពីលើប្រាក់កម្ចីដោយពុំយកការប្រាក់ សម្រាប់វិនិយោគលើការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធផ្គត់ផ្គង់អគ្គិសនីនៅតំបន់ជនបទ ដែលមានដង់ស៊ីតេប្រជាពលរដ្ឋរស់នៅទាប។ សេវាករត្រូវសងប្រាក់កម្ចីវិលស់ប្រចាំខែមក ម.អ.ជ. វិញ ក្នុងរយៈពេលយ៉ាងយូរ ៨ឆ្នាំ ឬមិនលើសពីអាណត្តិអាជ្ញាបណ្ណ។

សេវាករត្រូវដាក់ពាក្យ មក ម.អ.ជ. សម្រាប់ការស្នើសុំជួយទុនសម្រាប់ពង្រីក និងកែលម្អការផ្គត់ផ្គង់អគ្គិសនីនៅតំបន់ជនបទ តាមគំរូពាក្យស្នើសុំដែលមានស្រាប់នៅ ម.អ.ជ.។ ប្រសិនបើ ម.អ.ជ. និងអាជ្ញាធរអគ្គិសនីកម្ពុជាយល់ព្រមលើសំណើសុំ នោះកិច្ចសន្យាជួយទុននឹងត្រូវចុះហត្ថលេខារវាង ម.អ.ជ. និងសេវាករ។ សេវាករត្រូវសាង សង់ហេដ្ឋារចនាសម្ព័ន្ធផ្គត់ផ្គង់អគ្គិសនីក្រោមកិច្ចសន្យានេះ ដោយរាល់ការទូទាត់សម្ភារដែលទិញពីរោងចក្រអនុវត្តន៍ ដោយផ្ទាល់ពី ម.អ.ជ. តាមរយៈការបញ្ជាក់របស់សេវាករ។ ម.អ.ជ. នឹងពិនិត្យទូទាត់ថវិកាជួយទុនឲ្យទៅសេវាករ ស្របតាមវឌ្ឍនភាពហេដ្ឋារចនាសម្ព័ន្ធអគ្គិសនីដែលបានសាងសង់រួច។

ដើម្បីឲ្យកម្មវិធីនេះអនុវត្តន៍ទៅមានប្រសិទ្ធភាពខ្ពស់ សូម លោក/លោកស្រី ដែលជាម្ចាស់អាជ្ញាបណ្ណត្រូវផ្តល់ទិន្នន័យច្បាស់លាស់ ផែនទីភូមិសាស្ត្របែបប្រព័ន្ធឌីជីថល ដើម្បីពិនិត្យ និងផ្តល់ជូនជាកញ្ចប់រួម។ ព័ត៌មានលំអិតសូមចូល www.ref.gov.kh និងឈ្មោះ Channel Telegram **"នាយកដ្ឋានមូលនិធិអគ្គិសនីការូបនីយកម្មជនបទ"** និងព័ត៌មានបន្ថែមសូមទំនាក់ទំនងមកលោក ជុំ ចាន់តារា ទូរស័ព្ទលេខ 011 244-246 ឬលោក កែវ សីហា ទូរស័ព្ទលេខ 015 776-770 ឬទាក់ទងមក ម.អ.ជ. តាមទូរស័ព្ទលេខ 023 997-600 ឬទូរសារលេខ 023 997-601 ឬ



អគ្គិសនីកម្ពុជា: # ២ ផ្លូវ ព្រះយុគន្ធរ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ទូរស័ព្ទ: ០២៣ ៧២៣ ៩៧១ - ៧២៤ ៧៧១ ទូរសារ: (៨៥៥) ២៣ ៤២៦ ០១៨

អញ្ជើញមកទំនាក់ទំនងនៅនាយកដ្ឋាន ម.អ.ជ. មានទីតាំងនៅអាគារលេខ២០៥ ផ្លូវជាតិលេខ៥ សង្កាត់គីឡូម៉ែត្រលេខ៦ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ។

**ជ.ប្រតិភូរាជរដ្ឋាភិបាលកម្ពុជា**
**ទទួលបន្ទុកជា អគ្គនាយកអគ្គិសនីកម្ពុជា**
**អគ្គនាយករងទទួលបន្ទុកបច្ចេកទេសប្រព័ន្ធបណ្ដាញជនបទ**

ELECTRICITE DU CAMBODGE

**ជុន ពិសិដ្ឋ**

**<u>ចម្លងជូន៖</u>**

- ឯកឧត្តម ប្រតិភូរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកជា អគ្គនាយកអគ្គិសនីកម្ពុជា
- អាជ្ញាធរអគ្គិសនីកម្ពុជា ដើម្បី "គោរពជូនជ្រាប"
- អគ្គនាយករងអគ្គិសនីកម្ពុជា
- ឯកសារ-កាលប្បវត្តិ



អគ្គិសនីកម្ពុជា : # ២ ផ្លូវ ព្រះយុគន្ធរ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ទូរស័ព្ទ : ០២៣ ៧២៣ ៩៧១ - ៧២៤ ៧៧១ ទូរសារ : (៨៥៥) ២៣ ៤២៦ ០១៨

# KINGDOM OF CAMBODIA

## NATION RELIGION KING

ELECTRICITÉ DU CAMBODGE

Ref: 3252 EDC.REF

Phnom Penh, 24 April , 2024

## NOTICE

**Electricité du Cambodge (EDC)** honorably inform the public that under the highest consideration of improving the level of living standard of the population in rural area, RGC has the willingness to manage and strengthen the development of electricity sector in order to "reach and achieve sufficient, sustainable, reliable, quality and affordable electricity supply for all categories of consumers throughout the Kingdom of Cambodia". EDC has continuously provided grant to the Department of Rural Electrification Fund (hereinafter referred to as the "REF") in order to continuously implement **"Program for Providing Assistance to Develop Electricity Infrastructure in Rural Areas"**. This program is on-going program from 2013 and will also be implemented in 2024. The purpose of this program is to facilitate the private electricity supplier in rural areas, having legal license to supply electricity, to access fund for investment for expansion of electricity supply infrastructure to fully cover its authorized distribution areas so that all rural households therein have access to electricity for use. Under this program, REF will provide interest free loan for investment on electricity infrastructure in rural areas with medium density of population and; will provide part of the infrastructure cost as grant and part of the infrastructure cost as interest free assistance for investment on electricity infrastructure in rural area with low density of population. The private electricity supplier shall payback the interest free assistance in monthly installment within 8 years or within the validity of license whichever is earlier.

The electricity licensees have to apply to REF for the request on the Program of Providing Assistance to Develop Electricity Infrastructure in Rural Areas in the prescribed format. If REF and the Electricity Authority of Cambodia (EAC) accept the proposal, then the contract for this program will be signed between REF and the electricity licensees. Under the contract, the licensees are responsible to construct the electrical infrastructure and the payment for materials purchased from the factory are made directly from the REF, through the confirmation of the licensees. REF will verify the progress and make disbursements depending on the construction progress.

In order to implement this program more effectively, Please Mr / Mrs, the electricity licensees prepare the digital data via Geographic Information System (GIS) and submit it to REF for reviewing the eligibilities and then offering as a package. For further information, please visit our



Electricité du Cambodge: #2, St. Preah Yukunthor, Wat Phnom District, Khan Daun Penh, Phnom Penh Phone / Fax: (855) 23 426 018

website (**www.ref.gov.kh**) and Telegram Channel **"នាយកដ្ឋានមូលនិធិអគ្គិសនីការូបនីយកម្មជនបទ"** and or contact Mr. Chum Chandara via 011 244-246 or Mr. Keo Seyha via 015 776-770 or REF via 023 997-600 or fax 023 997-601 or visit REF office located at building No. 205, National road No. 5, Sangkat Kilometer 6, Khan Russeykeo, Phnom Penh.

Sincerely yours,

ELECTRICITE DU CAMBODGE

**Mr. Chun Piseth**

Deputy Managing Director of EDC

Recipients:

-Royal Government of Cambodia Delegate in charge as Managing Director of EDC

-Electricity Authority of Cambodia for "information "

-Deputy Managing Directors of EDC

- File-Archive.



Electricité du Cambodge: #2, St. Preah Yukunthor, Wat Phnom District, Khan Daun Penh, Phnom Penh Phone / Fax: (855) 23 426 018